**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ១៥ សសរ

# សេចក្ដីសម្រេច

# ស្ដីពី

# ការរៀបចំការចងសម្ព័ន្ធមេត្រីភាព
# រវាងអង្គភាពកងទ័ព ជាមួយស្ថាប័ន អង្គភាពស៊ីវិល

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកត/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើ ច្បាប់ស្ដីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០១ ស្ដីពីការកែ សំរួលតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- យោងតាមសំណូមពរការងារចាំបាច់

## សម្រេច

**ប្រការ ១ :** ត្រូវបានរៀបចំឱ្យមានការចងសម្ព័ន្ធមេត្រីភាពរវាង អង្គភាពកងទ័ព ជាមួយស្ថាប័ន អង្គភាពស៊ីវិល ដូចមានខាងក្រោមនេះ :

Chhor Phaly

| | |
|---|---|
| ១-យោធភូមិភាគ ទី ១ | សម្ព័ន្ធមេត្រីជាមួយ ចំការកៅស៊ូមេមត់ |
| ២-យោធភូមិភាគ ទី ២ និងកងពលតូចលេខ ២១ | សម្ព័ន្ធមេត្រីជាមួយ ចំការកៅស៊ូជប់ |
| ៣-យោធភូមិភាគទី ៣ និងមូលដ្ឋានជើងទឹករាម កងទ័ពជើងទឹក | សម្ព័ន្ធមេត្រីជាមួយ កំពង់ផែស្វយ័តក្រុងព្រះសីហនុ |
| ៤-យោធភូមិភាគ ទី ៤ និង កងពលតូចលេខ ១២ | សម្ព័ន្ធមេត្រីជាមួយ ក្រសួងទេសចរណ៍ និង អាជ្ញាធរអប្សរា |
| ៥-យោធភូមិភាគទី ៥ | សម្ព័ន្ធមេត្រីជាមួយ នាយកដ្ឋានជលផល |
| ៦-យោធភូមិភាគពិសេសនិងកងការពារព្រំដែន ៦០១ | សម្ព័ន្ធមេត្រីជាមួយ ក្រុងភ្នំពេញ |
| ៧-កងពលធំលេខ ២ | សម្ព័ន្ធមេត្រីជាមួយ ទីចាត់ការគយ និងរដ្ឋាករ |
| ៨-កងពលតូចអន្តរាគមន៍លេខ ១១ | សម្ព័ន្ធមេត្រីជាមួយ ក្រសួងពាណិជ្ជកម្ម |
| ៩-កងពលតូចអន្តរាគមន៍លេខ ១៤ | សម្ព័ន្ធមេត្រីជាមួយ ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល |
| ១០-កងពលតូចថ្មើរជើងលេខ ៣១ | សម្ព័ន្ធមេត្រីជាមួយ ក្រសួងធនធានទឹក និង ឧតុនិយម |
| ១១-កងពលតូចវិស្វកម្មលេខ ៧៩ | សម្ព័ន្ធមេត្រីជាមួយ ក្រសួងសាធារណការ និង ដឹកជញ្ជូន |
| ១២-កងពលតូចថ្មើរជើងលេខ ៥១ | សម្ព័ន្ធមេត្រីជាមួយ ក្រសួងសុខាភិបាល |
| ១៣-កងពលតូចថ្មើរជើងលេខ ៥២ | សម្ព័ន្ធមេត្រីជាមួយ ក្រសួងអភិវឌ្ឍន៍ជនបទ |
| ១៤-កងពលតូចថ្មើរជើងលេខ ៥៣ | សម្ព័ន្ធមេត្រីជាមួយ រតនាគារជាតិ |
| ១៥-កងពលតូចថ្មើរជើងលេខ ៤១ | សម្ព័ន្ធមេត្រីជាមួយ ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ |
| ១៦-កងពលតូចថ្មើរជើងលេខ ៤២ | សម្ព័ន្ធមេត្រីជាមួយ អគ្គិសនីកម្ពុជា |
| ១៧-កងពលតូចថ្មើរជើងលេខ ៤៣ | សម្ព័ន្ធមេត្រីជាមួយ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |
| ១៨-កងពលតូចអន្តរាគមន៍លេខ ១ | សម្ព័ន្ធមេត្រីជាមួយ ធនាគារជាតិនៃកម្ពុជា |
| ១៩-កងទ័ពជើងអាកាស | សម្ព័ន្ធមេត្រីជាមួយ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល |
| ២០-វរសេនាធំលេខ ៤២ | សម្ព័ន្ធមេត្រីជាមួយ ចំការកៅស៊ូស្នួល |
| ២១-កងពលតូចទ័ពពិសេសឆ័ត្រយោង ៩១១ | សម្ព័ន្ធមេត្រីជាមួយ ចំការកៅស៊ូបឹងកេត |
| ២២-កងពលតូចលេខ ៧០ | សម្ព័ន្ធមេត្រីជាមួយ ចំការកៅស៊ូចំការអណ្តូង |

២៣-កងការពារព្រំដែនលេខ ៤០១,៤០២,៤០៣ ចំណុះយោធភូមិភាគទី ៤ សម្ព័ន្ធមេត្រីជាមួយ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

២៤-កងវរសេនាតូចព្រំដែនលេខ៣០១,៣០២,៣០៣ នៅយោធភូមិភាគទី ៣ សម្ព័ន្ធមេត្រីជាមួយ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

២៥-កងការពារព្រំដែនលេខ ៥០១,៥០២,៥០៣,៥០៤,ចំណុះយោធភូមិភាគទី ៥ សម្ព័ន្ធមេត្រីជាមួយ នាយកដ្ឋានពន្ធដារ

២៦-កងវរសេនាតូចព្រំដែនលេខ ២០១,២០២,២០៣, នៅយោធភូមិភាគទី ២ សម្ព័ន្ធមេត្រីជាមួយ ចំការកៅស៊ូក្រែក

២៧-កងវរសេនាតូចព្រំដែនលេខ ១០១,១០២,១០៣, នៅយោធភូមិភាគទី ១ សម្ព័ន្ធមេត្រីជាមួយ ចំការកៅស៊ូពាមជាំង

២៨-អគ្គបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ សម្ព័ន្ធមេត្រីជាមួយ ទីស្តីការគណៈរដ្ឋមន្ត្រី ។

**ប្រការ ២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ អគ្គមេបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ ប្រធានស្ថាប័ន អង្គភាព មេបញ្ជាការអង្គភាព និងគ្រប់ក្រសួង ស្ថាប័ន អង្គភាព ដែលមានចែងក្នុងប្រការ ១ និងមានការពាក់ព័ន្ធ ត្រូវអនុវត្តសេចក្តីសម្រេចនេះចាប់ពីថ្ងៃ ចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេច និងឯកឧត្តមឧបនាយករដ្ឋមន្ត្រី
-ដូចប្រការ ២
-ឯកសារ-កាលប្បវត្តិ